# របាយការណ៍លទ្ធផលការងារឆ្នាំ២០២២
# និងលើកទិសដៅការងារឆ្នាំ ២០២៣
# របស់នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ

## សេចក្ដីផ្ដើម

បន្ទាប់ពីធូរស្រាលនៃការរាតត្បាតជំងឺកូវីដ១៩ មក ។ សង្គ្រាមរុស្សីឈ្លានពានប្រទេសអ៊ុយក្រែន បានចាប់ផ្ដើម និងអាកាសធាតុមានការប្រែប្រួលកាន់តែខ្លាំងឡើង គួបផ្សំនឹងជំនន់ទឹកភ្លៀងរដូវវស្សា នេះផងបានបង្កឲ្យមានវិបត្តិថាមពល អតិផរណានៃតម្លៃស្បៀងអាហារ និងការខូចខាតផលដំណាំ ហេដ្ឋារចនាសម្ព័ន្ធជនបទជាច្រើន ។ ទាំងនេះជាបន្ទុកដ៏ធ្ងន់របស់រាជរដ្ឋាភិបាលដែលត្រូវរ៉ាប់រងសម្រាប់សង្គ្រោះ និងស្ដារសេដ្ឋកិច្ច ឡើងវិញដោយប្រញាប់ប្រញាល់ជាទីបំផុត ។ ស្ថិតក្នុងបរិការនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានរួមចំណែកយ៉ាងសកម្មបំផុតចូលរួមដោះស្រាយតាមរយៈជំរុញការងារស្ដារហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ ហេដ្ឋារចនាសម្ព័ន្ធ ទឹកស្អាត អនាម័យ ជនបទព្រមទាំងសេវាដទៃទៀត ដើម្បីធានាឲ្យជីវភាពរស់នៅរបស់ប្រជាជនជនបទបានល្អប្រសើរឡើងវិញ បន្ទាប់ពីជួបបញ្ហាដូចបានរៀបរាប់ខាងលើ ។ នាយកដ្ឋានផែនការនិងទំនាក់ទំនងសាធារណៈ បានខិតខំរួមចំណែកក្នុងការកៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល បណ្ដាប្រទេសអាស៊ាន ពិសេសរៀបចំផែនការ ស្រូបទាញយកថវិកាជាតិឲ្យបានកាន់ច្រើនដើម្បីដោះស្រាយបញ្ហា និងការប្រឈមរបស់ប្រជាជននៅតាមតំបន់ជនបទនានាក្នុងប្រទេសកម្ពុជា សំដៅធានាប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្ដល់សេវាឲ្យបានឆាប់រហ័សទៅកាន់ប្រជាជនជនបទដែលកំពុងទទួលផលប៉ះពាល់ដោយវិបត្តិខាងលើទាន់ពេលវេលា ។

## 1. ស្ថានភាពមន្ត្រីរាជការ

- ចំនួនមន្ត្រីរាជការសរុប ៤៦ នាក់ ស្ត្រី ១១ នាក់ (ក្នុងនោះមន្ត្រីជាប់កិច្ចសន្យា ០១ រូប)
- ដឹកនាំដោយប្រធាននាយកដ្ឋាន ០១ រូប និងអនុប្រធាន ០៩ រូប (ស្ត្រី០១រូប)
- មន្ត្រីសហការជាមួយគម្រោងមានដូចខាងក្រោម៖

| ល.រ | ឈ្មោះ | ភេទ | តួនាទី | គម្រោងកម្មវិធី |
|---|---|---|---|---|
| ១ | ស្រ៊ន់ ពិធូ | ប | អនុប្រធាននាយកដ្ឋាន | គម្រោង TSLDP និង RRIP |
| ២ | ទាង ឆាយហៀង | ប | អនុប្រធាននាយកដ្ឋាន | គម្រោង CSADRMP |
| ៣ | សួស បូរិន្ទសក្តិ | ប | ប្រធានការិយាល័យ | កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ RIP III |
| ៤ | ហេង ស្រីស្រស់ | ស | ប្រធានការិយាល័យ | គម្រោង CSADRMP |
| ៥ | ហ៊ឹម សូរជាតិ | ប | អនុប្រធានការិយាល័យ | កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ RIP III |
| ៦ | គង់ សោភា | ស | អនុប្រធានការិយាល័យ | គម្រោង CSADRMP |

2. **លទ្ធផលសម្រេចបានរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន**

- ចូលរួមកិច្ចប្រជុំពិភាក្សាអន្តរក្រសួងស្តីពី សេចក្តីព្រាងនីតិវិធីប្រតិបត្តិការនៃការគ្រប់គ្រងរៀបចំ និងអនុវត្តគម្រោងវិនិយោគហិរញ្ញប្បទានថវិកាជាតិ " គម្រោងវិនិយោគផ្ទាល់ជំពូក២១ " នៅសណ្ឋាគារហាយយ៉ាត់ ភ្នំពេញ
- ចូលរួមកិច្ចប្រជុំពិនិត្យឡើងវិញស្តីពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្នែកទី២ ស្តីពីការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាមួយធនាគារអភិវឌ្ឍន៍អាស៊ីតាមអនឡាញ
- ចូលរួមកិច្ចប្រជុំពិភាក្សាបច្ចេកទេសលំអិតកញ្ចប់ថវិកាកំណែទម្រង់សម្រាប់ឆ្នាំ២០២៣ ជាមួយអគ្គលេខាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់អនុវត្ត MAP-4
- ចូលរួមកិច្ចប្រជុំពិនិត្យ "ច្បាប់ស្តីពីប្រព័ន្ធថវិកាថ្មី" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍វាយតម្លៃសូចនាករត្រីមាសទី៤នៃការអនុវត្តការងារកែទម្រង់ Q4-KPI
- រៀបចំផែនការដំណាក់កាលទី៤ សម្រាប់ការងារកែទម្រង់ MAP4
- រៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២២ នៃការអនុវត្តការងារកែទម្រង់ PFM
- ក្រុមការងារកែទម្រង់ក្រសួង បានជួបពិភាក្សាជាមួយជំនាញការ IMF ដើម្បីស្វែងយល់ពីនីតិវិធី នៃការរៀបចំផែនការ ថវិកា ការអនុវត្តថវិកា ទាំងថវិកាចរន្ត និងថវិកាវិនិយោគ របស់ក្រសួង ដើម្បី ធ្វើការវាយតម្លៃការគ្រប់គ្រងការអនុវត្តកម្មវិធី(PIMA) ដែលដឹកនាំដោយ **ឯកឧត្តម ម៉ា សុវណ្ណា**ប្រធាននាយកដ្ឋានផែនការនិងទំនាក់ទំនងសាធារណៈនិងជាជនបង្គោល PFM-MRD
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំថវិកា និងការផ្តល់សេវា សម្រាប់គោលនយោបាយសាធារណៈ បទពិសោធន៍ប្រទេសសឹង្ហបូរី " Public Policy for Budget Preparation and Service Delivery : Experience in Singapore " ពីថ្ងៃទី ២៨-៣០ ខែវិច្ឆិកា ឆ្នាំ២០២២ នៅ សកលវិទ្យាល័យលីក្វាន់យូរ ប្រទេសសឹង្ហបូរី រៀបចំដោយអគ្គលេខាធិការកែទម្រង់ ក្រសួងសេដ្ឋ កិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមប្រជុំពិភាក្សាការរៀបចំសៀវភៅគ្រប់គ្រងហិរញ្ញវត្ថុ FMM (Financial Management Mangenual ) រៀបចំដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមប្រជុំជាមួយអនុគណកម្មការរៀបចំសន្និបាតក្រសួង
- ដឹកនាំរៀបចំសិក្ខាសាលារៀបចំកម្មវិធីវិនិយោគសាធារណៈ PIP ២០២៣-២០២៥
- រៀបចំកិច្ចប្រជុំពិនិត្យសេចក្តីព្រាងស្តីពីការបង្កើតលេខាធិការដ្ឋានតាមដានត្រួតពិនិត្យនិងវាយតម្លៃគម្រោងវិនិយោគនិងថវិការដ្ឋ
- រៀបចំកិច្ចប្រជុំកសាងគម្រោងកិច្ចសហប្រតិបត្តិការកម្ពុជា-កូរ៉េ តាមរយៈ KOICA-Cambodia
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីក្របខណ្ឌយុទ្ធសាស្ត្រមេគង្គដោយវិទ្យាស្ថានមេគង្គ អន្តរជាតិ រៀបចំដោយក្រសួងពាណិជ្ជកម្ម
- ចូលរួមប្រជុំស្តីពីការចុះប្រមូលព័ត៌មានដើម្បីរៀបចំធ្វើសវនកម្ម និងអធិការកិច្ចក្រោមប្រធានបទលើកកម្ពស់អនាម័យជនបទ សម្រាប់ឆ្នាំ២០២១

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំថវិកាសមិទ្ធកម្មដែលរៀបចំដោយអគ្គនាយកដ្ឋានថវិកានិយកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ០២ លើក
- ចូលរួមសន្និបាតបូកសរុបការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ដឹកនាំការិយាល័យជំនាញចុះពិនិត្យលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣ មាន អង្គការ CGA , SC , Daikonai នៅខេត្តពោធិ៍សាត់ បាត់ដំបង
- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពីផែនការសកម្មភាពដោយនិរន្តរភាព Business Continuity Plan (BCP)រៀបចំដោយក្រសួងមុខងារសាធារណៈ
- ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាស្តីពី Strengthening the enabling Environment for Disaster Risk Financing (Phase 2 ) Project consultant mission (ADB) ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ចាន់ ដារ៉ុង** រដ្ឋលេខាធិការ
- ចូលរួមសិក្សាសាលាស្តីពីការសិក្សានិម្មានកម្មអន្តររដ្ឋាភិបាលរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នាCambodia Inter-Governmental Architecture study រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយធនាគារពិភពលោក
- ប្រជុំពិនិត្យលទ្ធផលនៃការអនុវត្តផែនការត្រីមាសទី១ របស់នាយកដ្ឋានផែនការ និងប្រកាសបែងចែកការងារជូនអនុប្រធាននាយកដ្ឋានផែនការនិងទំនាក់ទំនងសាធារណៈចំនួន ០២រូប
- រៀបចំកិច្ចប្រជុំពិភាក្សាការរៀបចំគម្រោងសំណើសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា សាធារណរដ្ឋកូរ៉េតាមរយៈ Mekong-Rok Cooperation Fund (MCKF) លើកទី១ ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ចាន់ ដារ៉ុង** រដ្ឋលេខាធិការ
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពី គោលការណ៍ណែនាំរៀបចំថវិកាសមិទ្ធកម្មនិងការសរសេរសូចនាករសមិទ្ធកម្ម ដែលមានអ្នកចូលរួមចំនួន ៨២ នាក់ ដោយប្រើប្រាស់ថវិកាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២២ នៅសណ្ឋាគារ Empress Angkor and Spar ខេត្តសៀមរាប ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិការប្រចាំការ និងជាប្រធានក្រុមការងារកែទម្រង់ក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួមកិច្ចប្រជុំជាមួយបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ADB Country Program Mission ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ចាន់ ដារ៉ុង** រដ្ឋលេខាធិការ ពិភាក្សាអំពីការផ្គត់ផ្គង់ទឹកស្អាត, ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ, និងការប្រែប្រួលអាកាសធាតុ តាមអនឡាញ
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំប្រគល់ពានរង្វាន់អាស៊ាន ប្រគល់ជូនអង្គការមិនមែនរដ្ឋាភិបាល ០១ និងសហគ្រាសឯកជន ០១ ដែលបានចូលរួមកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា តាមអនឡាញរៀបចំដោយប្រទេសឥណ្ឌូនេស៊ី
- រៀបចំកិច្ចប្រជុំ ពិនិត្យគម្រោងសំណើរបស់គ្រប់អង្គភាពនាយកដ្ឋាននានា គម្រោង Mekong-Rok Cooperation Fund (MKCF) ដឹកនាំដោយ **ឯកឧត្តម ចុង ផែត** អនុរដ្ឋលេខាធិការនៅទីស្តីការក្រសួង។ គម្រោងសំណើរៀបចំដោយអង្គភាពនាយកដ្ឋានក្រសួងមានចំនួន ០៣ គម្រោងមាន ទឹកប្រាក់សរុប ២,១៥៨,៨៦០ ដុល្លាអាមេរិក សម្រាប់រយៈពេល ៣ឆ្នាំ ២០២៣-២០២៥

- ចូលរួមកិច្ចប្រជុំ Mekong Institute Meeting for the Implementation Plan of the CLMV Framework តាមអនឡាញដឹកនាំដោយ វិទ្យាស្ថានមេគង្គអន្តរជាតិនៅប្រទេសថៃឡង់គី និងសម្របសម្រួលដោយក្រសួងពាណិជ្ជកម្ម
- ចូលរួមកិច្ចប្រជុំពិភាក្សាសមាសភាគនិងសូចនាករក្នុងវិធីសាស្ត្រវាស់វែងភាពងាយរងគ្រោះរបស់ប្រជាជនកម្ពុជា នៅទីរួមខេត្តសៀមរាបដែលរៀបចំដោយក្រសួងផែនការសហការជាមួយអង្គការ UNDP
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ផែនការសកម្មភាពរួមដំណាក់កាលទី៤ (MAP4) នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈPFMRP 2023-2027 តាមប្រព័ន្ធអនឡាញ ដឹកនាំដោយ **ឯកឧត្តម រស់ ស៊ីលវ៉ា** រដ្ឋលេខាធិការនិងជាអគ្គលេខាធិការ PFM
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ភាពជាដៃគូកម្រិតអន្តរក្រសួងលើសេចក្តីព្រាងនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់ភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមប្រព័ន្ធអនឡាញ ដឹកនាំដោយ **ឯកឧត្តម ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិល ២០២៣-២០២៥ និងគម្រោងចំណាយវិនិយោគថវិការដ្ឋជំពូក២១សម្រាប់ឆ្នាំ២០២៣ ដឹកនាំដោយ **ឯកឧត្តម ហាវ រតនៈ** អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចូលរួមសន្និសិទសារព័ត៌មានស្តីពីសមិទ្ធផលរបស់ក្រសួងអភិវឌ្ឍន៍ជនបទឆ្នាំ២០១៨-២០២២ នៅទីស្តីការគណៈរដ្ឋមន្ត្រី ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ជ្រុន ថេរ៉ាវ៉ាត** រដ្ឋលេខាធិការ
- ចូលរួមរៀបចំកិច្ចប្រជុំស្តីពីការរៀបចំរបាយការណ៍សង្ខេបនិងសូចនាករសំខាន់ៗដែលជាសមិទ្ធផល៥ឆ្នាំ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា នៅទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមកិច្ចប្រជុំអាស៊ានស្តីពី ASEAN Master Plan on Rural Development 2022-2026 តាមប្រព័ន្ធ Zoom ដឹកនាំដោយ **ឯកឧត្តម សៅ ជីវ័ន្ត** រដ្ឋលេខាធិការ
- ចូលរួមកិច្ចប្រជុំលើកទី៥ ស្តីពីការពិភាក្សាពីវិធីវាស់វែងភាពងាយរងគ្រោះនៅកម្ពុជាលើពហុវិមាត្រ នៅសណ្ឋាគារសោម៉ាអង្គរ ខេត្តរៀមរាប រៀបចំដោយក្រសួងផែនការ
- **ឯកឧត្តម ម៉ា សុវណ្ណា** ប្រធាននាយកដ្ឋានផែនការនិងទំនាក់ទំនងសាធារណៈ ដឹកនាំរៀបកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជាមួយនាយកដ្ឋានជំនាញ និងអង្គការ មិនមែនរដ្ឋាភិបាលលើវិស័យទឹកស្អាត និងអនាម័យជនបទ
- **ឯកឧត្តម ម៉ា សុវណ្ណា** ប្រធាននាយកដ្ឋានផែនការនិងទំនាក់ទំនងសាធារណៈដឹកនាំបេសកកម្មចុះពិនិត្យសមិទ្ធផលកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួន ០៥ នៅខេត្តកំពង់ឆ្នាំង, ខេត្តពោធិសាត់, ខេត្តបាត់ដំបង, ខេត្តប៉ៃលិន និងខេត្ត បន្ទាយមានជ័យ
- ចូលរួមប្រជុំពិភាក្សាចរចាថវិកាឆ្នាំ២០២៣របស់ក្រសួងអភិវឌ្ឍន៍ជនបទកម្រិតគោលនយោបាយដឹកនាំដោយ**ឯកឧត្តមបណ្ឌិត សួស គង់** រដ្ឋលេខាធិកាប្រចាំការ
- រៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារសហប្រតិបត្តិការជាមួយ NGOs រយៈពេល ៥ឆ្នាំ ២០១៨-២០២២ និងបូកសរុបរបាយការណ៍ឆមាសទី១ ឆ្នាំ២០២២។

3. **លទ្ធផលសម្រេចបានរបស់ការិយាល័យជំនាញទាំង ០៥ មានសកម្មភាពដូចខាងក្រោម ៖**

**3.1 ការិយាល័យកិច្ចការទូទៅ**

- បានទទួលលិខិតចូលទូទៅចំនួន ៤៣៨ ច្បាប់
- បានទទួលលិខិតចូលក្នុងអង្គភាពចំនួន ២២៨ ច្បាប់
- បានទទួលលិខិតចូលក្រៅក្រសួងចំនួន ១៥០ ច្បាប់
- លិខិតចេញទូទៅចំនួន ២០៧ ច្បាប់
- លិខិតបញ្ជូនចំនួន ២២ ច្បាប់
- លិខិតបេសកកម្មចំនួន ៧៧ ច្បាប់
- លិខិតអញ្ជើញចំនួន ៣៧ ច្បាប់
- លិខិតបង្គាប់ការចំនួន ០០ ច្បាប់
- លិខិតសុំច្បាប់ចំនួន ០៤ ច្បាប់
- លិខិតប្រកាសចំនួន ០៨ ច្បាប់
- លិខិតលុបឈ្មោះមន្រ្តីរាជការចំនួន ០០ ច្បាប់
- គ្រប់គ្រងវត្តមានប្រចាំខែរបស់មន្រ្តីរាជការ
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសរបស់នាយកដ្ឋាន ។

**3.2 ការិយាល័យផែនការ និងស្ថិតិ**

- រៀបចំ និងសម្របសម្រួលសិក្ខាសាលាស្តីពី ការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ ស.វ.ក) (.៣ឆ្នាំរំកិល ២០២៣ ២០២៥-និងសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីគោលការណ៍ណែនាំនៃការរៀបចំថវិកាព័ត៌មានសមិទ្ធកម្មរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួង និងតាមប្រព័ន្ធអនឡាញ Zoom
- បានបញ្ជូនឯកសារកម្មវិធីវិនិយោគសាធារណៈ ២០២៥-២០២៣ ៣ឆ្នាំរំកិល (.ស.វ.ក) ដែលរួមមានគម្រោងស្នើសុំថ្មីចំនួន ៣៨ និងគម្រោងកំពុងដំណើរការចំនួន ២៧ គម្រោងទៅក្រសួងផែនការ
- ចូលរួម និងសម្របសម្រួលសិក្ខាសាលាស្តីពី ស្តីពីគោលការណ៍ណែនាំការរៀបចំថវិកាសមិទ្ធកម្ម និងការសរសេរសូចនាករសមិទ្ធកម្មដែលរៀបចំដោយ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ) PFM-MRD) នៅសណ្ឋាគារអេមព្រីសអង្គរ ខេត្តសៀមរាប
- ចូលរួម និងសម្របសម្រួលសិក្ខាសាលា ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៣ - ២០២៥ និងថវិកាសមិទ្ធកម្មឆ្នាំ២០២៣ នៅខេត្តព្រះសីហនុ ដែលរៀបចំដោយ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រសួងអភិវឌ្ឍន៍ជនបទ
- ចូលរួម និងសម្របសម្រួលសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២៣ ២០២៥-និងគម្រោងថវិកាឆ្នាំ២០២៣ លើវិស័យផ្គត់ផ្គង់ទឹកស្អាត និង

អនាម័យជនបទ នៅខេត្តសៀមរាប ទីស្ដីការក្រសួង និងតាមប្រព័ន្ធអនឡាញ Zoom ចំនួន ០៣ លើកដែលគាំទ្រថវិកាដោយ អង្គការយូនីសេហ្វ

- ចូលរួមសិក្ខាសាលាវគ្គបណ្ដុះបណ្ដាល និងកិច្ចប្រជុំការងារផែនការ ដែលរៀបចំដោយក្រសួងផែនការ បានចំនួន ១៧ លើក នៅទីស្ដីការការក្រសួងផែនការ រាជធានីភ្នំពេញ ខេត្តសៀមរាប និងតាមប្រព័ន្ធអនឡាញ
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួង នៅទីស្ដីការក្រសួង និងតាមប្រព័ន្ធវីឌីអូ Zoom
- បានចូលរួមពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងសេចក្ដីសម្រេចស្ដីពី ការកែសម្រួលរបៀបរបបការងារ និងការបែងចែកភារកិច្ចថ្នាក់ដឹកនាំរបស់នាយកដ្ឋាន
- ចូលរួមវគ្គបណ្ដុះបណ្ដាល និងកិច្ចប្រជុំ ស្ដីពីការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងតាមប្រព័ន្ធវីឌីអូ Zoom បានចំនួន ០៦ លើក
- ចុះផ្សព្វផ្សាយ ស្ដីពីការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ ២០២៣ ៣ឆ្នាំរំកិល (.ស.វ.ក)-២០២៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅខេត្តចំនួន ០៤ រួមមាន ៖ ខេត្តបន្ទាយមានជ័យ ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង
- ចូលរួមកិច្ចប្រជុំជាមួយក្រុមការងារគម្រោងគ្រប់គ្រងប្រព័ន្ធទិន្នន័យ សម្រាប់ការគ្រប់គ្រងប្រព័ន្ធទិន្នន័យ ការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ )MRD-MIS) តាមប្រព័ន្ធអនឡាញ Zoom និងដោយផ្ទាល់ចំនួន ០៤ លើក
- ចូលរួមវេទិកាស្ដីពីសន្តិសុខស្បៀង និងអាហាររូបត្ថម្ភលើកទី និងសិក្ខាសាលាដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ បានចំនួន ០៣ លើក នៅរាជធានីភ្នំពេញ និងតាមប្រព័ន្ធអនឡាញ Zoom
- ចូលរួមកិច្ចប្រជុំ របស់ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅ ទីស្ដីការក្រសួង និងតាមរយៈប្រព័ន្ធវីឌីអូ Zoom ចំនួន ០៣ លើក
- ចូលរួមកិច្ចប្រជុំស្ដីពី ការពិនិត្យ និងពិភាក្សាអំពីការរៀបចំសរសេរឯកសារទស្សនទានគម្រោង )Project Concept Paper ) សម្រាប់ជុំទី៦ ក្នុងក្របខ័ណ្ឌមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ នៅទីស្ដីការក្រសួង
- ចូលរួមសិក្ខាសាលាស្ដីពី ការផ្សព្វផ្សាយក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនទីបង្ហាញផ្លូវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍និង ២០៣០ កម្ពុជា (.ន.ប.វ) ពិគ្រោះយោបល់លើគោលការណ៍ ណែនាំស្ដីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគោលនយោបាយ វ .ន.ប.ដែលរៀបចំដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍

- បានចុះណែនាំអំពីគោលការណ៍ការរៀបចំថវិកាសមិទ្ធកម្ម នៅខេត្តចំនួន ០៧ រួមមាន៖ ខេត្តកែប ខេត្តកំពត ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង និងខេត្តកំពត
- ចូលរួមសម្របសម្រួលសិក្ខាសាលារៀនសូត្រ និងចែករំលែកចំណេះដឹងអំពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យសម្រាប់វិស័យផ្គត់ផ្គង់ទឹក ការសំអាត និងលើកកម្ពស់អនាម័យជនបទ )MRD-MIS) នៅខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងតាមប្រព័ន្ធអនឡាញ Zoom ដែលរៀបចំដោយ ក្រុមការងារ MRD-MIS
- សម្របសម្រួល និងរៀបចំសំណើសុំកិច្ចសហការផ្តល់ទិន្នន័យអំពីតម្រូវការបណ្តុះបណ្តាល និងវិក្រឹតការសមត្ថភាពមន្ត្រីរាជការ លើជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០២៣
- បានរៀបចំសំណើសុំចាត់បញ្ជូនឥស្សរជន០១រូប ដើម្បីចូលរួមជាសមាជិកគណៈកម្មការអន្តរក្រសួង នៃគណៈកម្មាការពិសេសតាមដានការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍ តាមរយៈការស្នើសុំរបស់ក្រសួងផែនការ
- ចូលរួមកិច្ចប្រជុំលើសេចក្តីព្រាងលើកចុងក្រោយ ស្តីពីការរៀបចំសរសេរឯកសារទស្សនទានគម្រោង )Project Concept Paper) សម្រាប់ជុំទី៦ ក្នុងក្របខ័ណ្ឌមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គសាធារណរដ្ឋកូរ៉េ នៅទីស្តីការក្រសួង - ចំនួន ០២ លើក
- បានរៀបចំ និងដាក់ស្នើគម្រោង ការកសាងសមត្ថភាពនៅក្នុងសហគមន៍ជនបទ ដើម្បីពង្រឹងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ DBST ក្នុងក្របខណ្ឌមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ
- បានរៀបចំសំណើរសុំផ្អាកការអនុវត្តគម្រោងកែលម្អ និងកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងស្ថិតិជនបទក្នុងឆ្នាំ២០២២ និងបន្តអនុវត្តនៅឆ្នាំ២០២៣ ដោយបញ្ចូលក្នុងថវិកាកម្មវិធីរបស់នាយកដ្ឋាន។
- បូកសរុបទិន្នន័យភាគរយសូចនាករ សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្នុងរយដោយទិន្នន័យខាងលើផ្តល់ជូន ដោយមន្ទីរអភិវឌ្ឍន៍ជនបទ (២០២២-២០១៨) ពេល៥ឆ្នាំ: រាជធានី២៥ ខេត្ត ទាំង-
- សម្របសម្រួល ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣និងថវិកាព័ត៌មាន ២០២៥- សមិទ្ធកម្មឆ្នាំ២០២៣របស់ថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត-
- ចូលរួមកិច្ចប្រជុំពិភាក្សាលើគម្រោងផែនការថវិកាឆ្នាំ២០២៣ របស់ក្រសួងស្ថាប័ននៃរាជ-រដ្ឋាភិបាល) កម្រិតថ្នាក់ដឹកនាំ (ដើម្បីពិនិត្យ និងសម្រេចចុងក្រោយលើលទ្ធផលនៃកិច្ចប្រជុំកម្រិតបច្ចេកទេសដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និង (ដែលបានប្រព្រឹត្តទៅកាលពីខែកក្កដា) ហិរញ្ញវត្ថុនៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ចូលរួមសិក្ខាសាលាស្តីពី «ការរៀបចំថវិកាឆ្លើយតបយេនឌ័រ ក្នុងបរិបទ បម្រែបម្រួលអាកាសធាតុ / ការកាត់បន្ថយហានីភ័យគ្រោះមហន្តរាយ » របស់ UN WOMEN តាមរយៈប្រព័ន្ធអនឡាញ Zoom

- ចូលរួមសិក្ខាសាលាស្តីពី "Targeted Poverty Alleviation for Better Life in the Lancang-Mekong Region: Sharing Experiences" ដែលរៀបចំដោយ វិទ្យាស្ថានមេគង្គប្រទេសថៃ តាមរយៈប្រព័ន្ធអនឡាញ Zoom
- ចូលរួមកិច្ចប្រជុំអន្តរក្រសួង ផ្នាំរំកិល ៣ ដើម្បីពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ " ២០២៣-២០២៥ ដែលរៀបចំដោយក្រសួងផែនការ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ និងលើកទី២ តាមប្រព័ន្ធអនឡាញ Zoom ដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី
- ចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសលើគម្រោងផែនការចំណូល ២០២៣ ចំណាយថវិកាឆ្នាំ-នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមសិក្ខាសាលាស្តីពី ដែលរៀបចំ "ការផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី" ដោយនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ នៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំប្រចាំត្រីមាស របស់នាយកដ្ឋាននៅទីស្តីការក្រសួង ចំនួន ០៣ លើក
- ប្រជុំផ្ទៃក្នុង ដើម្បីបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងរៀបចំផែនការសកម្មភាពរបស់ការិយាល័យសម្រាប់ឆ្នាំ២០២៣
- បានរៀបចំសំណើរសុំគោលការណ៍រៀបចំសិក្ខាសាលាចំនួន ០២ ស្តីពី ការពិនិត្យឡើងវិញលទ្ធផលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០២៣និងថវិកាព័ត៌មានសមិទ្ធ ២០២៥-កម្មឆ្នាំ២០២៣ និងការបូកសរុបឡើងវិញនៃការអនុវត្តថវិកាកម្មវិធីឆ្នាំ២០២២ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលគ្រោងនិងធ្វើនៅក្នុងខែធ្នូ ឆ្នាំ២០២២
- បានរៀបចំសំណើសុំកិច្ចសហការជាមួយរដ្ឋបាលខេត្តក្រចេះ និងខេត្តរតនគិរី ក្នុងការប្រមូលទិន្នន័យសម្រាប់រៀបចំគោលការណ៍ណែនាំប្រតិបត្តិការ និងការអភិវឌ្ឍផែនការហិរញ្ញប្បទានសាធារណៈជាតិ សម្រាប់វិស័យផ្គត់ផ្គង់ទឹកជនបទ ជូនជំនាញការ UNICEF
- ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី ការរៀបចំធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួង
- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការងារ ផែនការថវិកា យេនឌ័រ ហិរញ្ញវត្ថុ កសិកម្ម បានចំនួន ០៤ នៅរាជធានីភ្នំពេញ និងតាមប្រព័ន្ធអនឡាញ
- ចូលរួមកិច្ចសន្ទនាគោលនយោបាយ វេទិកាគោលនយោបាយថ្នាក់ជាតិបានចំនួន ០៤ លើក នៅរាជធានីភ្នំពេញ
- សម្របសម្រួលការរៀបចំរបាយការណ៍របស់មន្ទីរអភិវឌ្ឍន៍ជនបទទាំង ២៥ រាជធានី-ខេត្ត ស្តីពីការបូកសរុបលទ្ធផលការងាររបស់មន្ទីរក្នុងឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៣ ដើម្បីរៀបចំសន្និបាទប្រចាំឆ្នាំរបស់ក្រសួង ។

### 3.3 ការិយាល័យតាមដាន និងវាយតម្លៃ

- រៀបចំតារាងតាមដានផែនការសកម្មភាពរបស់គ្រប់អង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ

- ចុះត្រួតពិនិត្យផែនការសកម្មភាពការងារមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តស្ទឹងត្រែង
- ចូលរួមវគ្គបណ្តុះបណ្តាលកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម
- ចូលរួមកម្មវិធីប្រជុំស្តីពី របាយការណ៍សកម្មភាពការងារឆ្នាំ២០២១ នៃគម្រោងស្តីពីការបង្កើត និងប្រតិបត្តិការមជ្ឈមណ្ឌលសហប្រតិបត្តិការរដ្ឋាភិបាលឌីជីថល និងពិធីប្រគល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនសិក្ខាកាមដែលបានបញ្ចប់ការសិក្សា BPR/ISP ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ធ្វើការពិនិត្យផែនការសកម្មភាពរបស់មន្ទីររាជធានី ខេត្តដែលបានផ្ញើមក
- រៀបចំតារាងសូចនាករសមិទ្ធកម្ម ដើម្បីឆ្លើយតបតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការរៀបចំថវិកាសមិទ្ធកម្ម ។
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំថវិកាសមិទ្ធកម្ម
- ចុះត្រួតពិនិត្យផែនការសកម្មភាពរបស់មន្ទីរអភិវឌ្ឍន៍ខេត្តព្រះវិហារ
- ស្នើសុំគ្រប់អង្គភាពក្រោមឱវាទក្រសួងរៀបចំរបាយការណ៍សមិទ្ធកម្មត្រីមាសទី១
- បញ្ចូលរបាយការណ៍សមិទ្ធកម្មត្រីមាសទី១ អង្គភាពក្រោមឱវាទក្រសួងបំពេញ
- កែសម្រួលទម្រង់របាយការសមិទ្ធកម្ម
- ចុះត្រួតពិនិត្យផែនការសកម្មភាពរបស់មន្ទីរអភិវឌ្ឍន៍ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង
- ចូលរួមសិក្ខាសាលាអន្តរក្រសួងជាមួយក្រសួងផែនការ និងក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍។
- ចុះត្រួតពិនិត្យផែនការសកម្មភាពរបស់មន្ទីរអភិវឌ្ឍន៍ខេត្តរតនៈគីរី ។
- ចូលរួមសិក្ខាសាលា នៅខេត្តសៀមរាប និងខេត្តព្រះសីហនុ
- ចូលរួមកិច្ចប្រជុំវាយតម្លៃថវិកាពាក់កណ្តាលឆ្នាំ២០២២ របស់ក្រុមការងារកំណែទម្រង់សាធារណៈលើកទី៤
- ចូលរួមវគ្គបណ្តុះបណ្តាលតាមរយៈវីឌីអូអនឡាញ ជាមួយសាធារណៈរដ្ឋកូរ៉េខាងត្បូងរយៈពេល៩ថ្ងៃ
- ប្រជុំពិភាក្សាការងាររបស់ការិយាល័យតាមដាន និងវាយតម្លៃ ស្តីការការងាររបស់ការិយាល័យ និងបញ្ជីវត្តមាននិងការពង្រឹងសមត្ថភាពការងារ
- ចូលរួមប្រជុំបូកសរុបការងារ ៩ខែដើមឆ្នាំ២០២២ របស់នាយកដ្ឋាន
- ចូលរួមកិច្ចប្រជុំលើរបាយការណ៍តម្រូវការបណ្តុះបណ្តាល ជាមួយក្រសួងផែនការ
- ចូលរួមរៀបចំតារាងបូកសរុប សមិទ្ធផល ៥ឆ្នាំ ២០១៨២០២២ ស-ម្រាប់ជូននាយកដ្ឋានជំនាញ និងអង្គភាពមន្ទីរក្រោមឱវាទ។ ចូលរួមកម្មវិធីផ្សព្វផ្សាយស្តីពី ដាក់ឲ្យប្រើប្រាស់នីតិវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្មី និងការពង្រីកវិសាលភាពគ្របដណ្តប់ដល់គ្រួសារងាយរងហានិភ័យ រៀបចំឡើងដោយក្រសួងផែនការ
- រៀបចំរបាយការសមិទ្ធកម្មត្រីមាសទី៣

- បានធ្វើទម្រង់បទបង្ហាញ ដល់អង្គភាពក្រោមឱវាទក្រសួងទាំងអស់ធ្វើការបូកសរុបលទ្ធផលសម្រេចបានក្នុងរយៈពេលមួយឆ្នាំ និងលៈើកផែនការបន្តនៅឆ្នាំ២០២៣
- ធ្វើការពិនិត្យ មើលលទ្ធផលដែលសម្រេចបាន ធៀបនឹងថវិការបស់អង្គភាពនីមួយៗ
- ធ្វើការបូកសរុបលទ្ធផលដែលសម្រេចបានដាក់ជូនអង្គសន្និបាតក្រសួង

## 3.4 ការិយាល័យបច្ចេកវិទ្យាព័ត៌មាន

- បាន Upload & Post ឯកសារចូលទៅក្នុងគេហទំព័រក្រសួងចំនួន ៩៥ ដង
- ចូលរួម និងរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២
- ចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការមជ្ឈមណ្ឌលសហប្រតិបត្តិការរដ្ឋាភិបាលឌីជីថល និងចូល
- រួមវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំដំណើរការលំហូរការងារសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធឌីជីថល
- រៀបចំសម្ភារបច្ចេកទេសនៅសាលប្រជុំធំជាន់ទី ៨ ដើម្បីត្រៀមសន្និបាតក្រសួងនៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២២ នាពេលខាងមុខនេះ
- ចូលរួមកិច្ចប្រជុំស្តីពី របាយការណ៍សកម្មភាពការងារឆ្នាំ២០២១ នៃគម្រោងស្តីពីការបង្កើតនិងប្រតិបត្តិការមជ្ឈមណ្ឌលសហប្រតិបត្តិការរដ្ឋាភិបាលឌីជីថល និងពិធីប្រគល់វិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនសិក្ខាកាមដែលបានបញ្ចប់ការសិក្សា BPR/ISP ក្រោមអធិបតីភាព **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- រៀបចំសម្ភារបច្ចេកទេសនៅសាលប្រជុំជាន់ទី១, ជាន់ទី៣) បន្ទប់ ៣០៥(, ជាន់ទី៧) បន្ទប់ ៧០៦ (និងសាលប្រជុំធំជាន់ទី៨ ដើម្បីត្រៀមសន្និបាតក្រសួងនៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០២២ នាពេលខាងមុខនេះ
- ជួសជុលកុំព្យូទ័រ និងដំឡើងកម្មវិធី Ms. Office ជូនមន្ត្រីក្នុងក្រសួងបានចំនួន ១១៦ គ្រឿង
- រៀបចំកិច្ចប្រជុំនៅសាលប្រជុំធំជាន់ទី៨ ស្តីពី "កិច្ចប្រជុំការងារ" ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី
- រៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ Zoom ស្តីពី "គណៈកម្មការដឹកនាំនៃ គណៈកម្មាធិការភាពជាដៃគូសកលនៃការសំអាត និង ទឹកស្អាត សម្រាប់ទាំងអស់គ្នា ) Sanitation and Water for All )" ជូនឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ចំនួន ០២លើក
- រៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ Zoom ជូនថ្នាក់ដឹកនាំចំនួន ៣៥ លើក
- ចូលរួមកិច្ចប្រជុំ ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- ត្រួតពិនិត្យ និងដោះស្រាយបញ្ហា Printers របស់នាយកដ្ឋាននានាក្នុងក្រសួងបានចំនួន ៧៧ ដង
- ដោះស្រាយបញ្ហា Internet / Network របស់នាយកដ្ឋាននានាក្នុងក្រសួងបានចំនួន ៩២ ដង
- តបណ្តាញ Internet / Network ជូនថ្នាក់ដឹកនាំក្រសួងបានចំនួន ០៤ បន្ទប់

- រៀបចំដំឡើងឧបករណ៍ប្រជុំ Online បន្ទប់ ៧០៥
- រៀបចំតបណ្តាញ Internet / Network បន្ទប់ ឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំត្រីមាសទី៣ របស់នាយកដ្ឋាន
- ធ្វើបច្ចុប្បន្នភាពទិន្នន័យលើ MRD Mobile App
- ធ្វើបច្ចុប្បន្នភាពលើ ម៉ាស៊ីន Server
- បានធ្វើបច្ចុប្បន្នភាពគេហទំព័រក្រសួង។

## 3.5 ការិយាល័យអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ

### ១ការងារអង្គការមិនមែនរដ្ឋាភិបាល .

- បានរៀបចំបន្តកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងក្រសួងអភិវឌ្ឍន៍ជនបទ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ១៦ កិច្ចព្រមព្រៀង
- បានរៀបចំលិខិតគាំទ្របន្តអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ១១លិខិត។
- បានរៀបចំលិខិតគាំទ្រ ទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សម្រាប់អង្គការមិនមែនរដ្ឋាភិបាលបានចំនួន ០៤លិខិត
- បានរៀបចំលិខិតគាំទ្រ ទៅអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា សម្រាប់អង្គការមិនមែនរដ្ឋាភិបាល បានចំនួន ០៤លិខិត
- បានរៀបចំលិខិតសុំអន្តរាគមន៍ ដើម្បីចុះបញ្ជីសុំស្លាកលេខ ONG សម្រាប់អង្គការមិនមែនរដ្ឋាភិបាលបានចំនួន ១០លិខិត
- បានរៀបចំលិខិតគាំទ្រ ដើម្បីធ្វើការប្តូរស្លាកលេខពីទម្រង់ចាស់ ONG 202ទៅទម្រង់ថ្មី ONG2- 1 0001 សម្រាប់អង្គការមិនមែនរដ្ឋាភិបាល បានចំនួន ០២លិខិត
- បានរៀបចំលិខិតសុំផ្លាស់ប្តូរទិដ្ឋាការពីប្រភេទ E មកប្រភេទ C ជូនបុគ្គលិកចំនួន០១ រូប សម្រាប់អង្គការ មិនមែនរដ្ឋាភិបាលបានចំនួន ០៣លិខិត
- បានរៀបចំលិខិតគាំទ្រសុំផ្លាស់ប្តូរទិដ្ឋាការពីប្រភេទ EB មកប្រភេទ C ជូនបុគ្គលិកចំនួន ០១នាក់ និងសមាជិកគ្រួសារចំនួន ០២នាក់ របស់អង្គការ អេ ស៊ី អា/ការីតាសអូស្ត្រាលី ចំនួន០១ លិខិត
- បានរៀចចំសំណើសុំផ្តល់យោបល់ ក្នុងការចូលរួមក្នុងពិធីបិទ និងប្រគល់-ទទួលសមិទ្ធផលគម្រោង" ភាពធន់នឹងគ្រោះមហន្តរាយ និងការគ្រប់គ្រងធនធានទឹកនៅប្រទេសកម្ពុជា "របស់អង្គការអាក់សិនអេតកម្ពុជា
- សំណើសុំហត្ថលេខាលើបណ្ណសរសើរជូនអង្គការ ការីតាសអូស្ត្រាលី និងអង្គការ Saemaul Globalization Foundation

- សំណើសុំអនុញ្ញាតិចូលរួមកម្មវិធីសិក្ខាសាលាស្តីពីការផ្សព្វផ្សាយលទ្ធផលនៃការវាយតម្លៃបញ្ចប់គម្រោង"លើកកម្ពស់ទីផ្សារសម្រាប់កសិករខ្នាតតូច "របស់អង្គការហេហ្វឺអន្តរជាតិកម្ពុជា។
- បានរៀបចំសំណើសុំអន្តរាគមន៍ដើម្បីនាំចូលរថយន្ត ដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋរបស់អង្គការ បានចំនួន ០១លិខិត

## ២.ការងារអាស៊ាន

- បានរៀបចំរបាយការណ៍វឌ្ឍនភាព សមិទ្ធផលការងារដែលបានសម្រេចកន្លងមក នៃកិច្ចសហប្រតិបត្តិការកម្ពុជា-នូវែលសេឡង់ ក្នុងវិស័យអភិវឌ្ឍន៍ជនបទ
- បានរៀបចំ ករណីសំណើសុំព័ត៌មាន និងរៀបចំខ្លឹមសារអត្ថបទ ពាក់ព័ន្ធនឹងសកម្មភាពនានាតាមវិស័យ ក្រោមសហគមន៍សង្គម-វប្បធម៌អាស៊ាន ដែលកម្ពុជាបានចូលរួមចំណែកចាប់ឆ្នាំ១៩៩៩។
- បានរៀបចំសំណើសុំចាត់បេក្ខភាពជាថ្នាក់ដឹកនាំទទួលបន្ទុកកិច្ចការអាស៊ានចូលរួមក្នុងកិច្ចប្រជុំជាមួយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីខាងកើត) Economic Research Institute For ASEAN and East Asia-ERIA) តាមប្រព័ន្ធអនឡាញ) Zoom)
- បានរៀបចំសំណើសុំអញ្ជើញឧត្តមមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ានចូលរួមកិច្ចប្រជុំសម្របសម្រួលអន្តរក្រសួងក្រោមសហគមន៍សង្គម-វប្បធម៌អាស៊ាន។
- បានរៀបចំ សំណើសុំគោលការណ៍ប្រជុំ ស្តីពី ការរៀបចំគម្រោងស្នើសុំហិរញ្ញប្បទាន ឥតសំណងពីរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ សម្រាប់ឆ្នាំសារពើពន្ធ ២០២៤
- សំណើសុំការបញ្ជាក់លើបញ្ជីព្រឹត្តការណ៍អម នៃសសរស្តម្ភសហគមន៍សង្គម-វប្បធម៌អាស៊ាន
- ករណីសំណើសុំផ្តល់ធាតុចូល លើសេចក្តីព្រាងដំបូងនៃផែនការសកម្មភាពថ្មី នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា) ២០២៣-២០២៧(របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានរៀបចំករណីសំណើសុំផ្តល់មតិលើសេចក្តីព្រាងផែនការសកម្មភាព ដើម្បីអនុវត្តភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-សហភាពអឺរ៉ុប) ឆ្នាំ២០២៣-២០២៧(
- បានរៀបចំសំណើសុំបើកគណនីសម្រាប់រៀបចំវេទិកាអាស៊ាន
- បានរៀបចំសំណើសុំចុះហត្ថលេខាលើកិច្ចសន្យាប្រើប្រាស់ថវិការ សម្រាប់រៀបចំវេទិកាអាស៊ានស្តីពីភាពជាអ្នកដឹកនាំក្នុងការអភិវឌ្ឍន៍ជនបទ និងលុបបំបាត់ភាពក្រីក្រ
- បានរៀបចំសំណើសុំគោលការណ៍អនុញ្ញាតឲ្យឧត្តមមន្ត្រី និងមន្ត្រីបង្គោលទទួលបន្ទុកការងារអាស៊ាន ដើម្បីចូលរួមក្នុងកិច្ចប្រជុំឧត្តមមន្ត្រីសហគមន៍សង្គម-វប្បធម៌អាស៊ានលើកទី៣២ និងកិច្ចប្រជុំក្រុម ប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ានលើកទី២៧ តាមប្រព័ន្ធអនឡាញ
- បានរៀបចំសុំណើសុំគោលការណ៍អនុញ្ញាតដើម្បី អញ្ជើញប្រធានសមាគមសម្របសម្រួល និងអភិវឌ្ឍន៍សង្គម និងអគ្គនាយកក្រុមហ៊ុនអេមរ៉ាយស៍ខេមបូឌា ចូលរួមកម្មវិធីប្រគល់ពានរង្វាន់ភាពជាអ្នកដឹកនាំសអាស៊ានលើកទី៥ តាមប្រព័ន្ធអនឡាញ
- បានរៀបចំសំណើសុំគោលការណ៍អនុញ្ញាតដើម្បីឲ្យឧត្តមមន្ត្រីទទួលបន្ទុកការងារអាស៊ានចូលរួមកម្មវីធីប្រគល់ពានរង្វាន់អាស៊ានលើកទី៥ ស្តីពីការងារអភិវឌ្ឍន៍ជនបទ និងលុបបំបាត់ភាពក្រីក្រ និងស្នើសុំអនុញ្ញាតអញ្ជើញប្រធានសមាគមនសម្របសម្រួល និងអភិវឌ្ឍន៍សង្គម និងអគ្គនាយកក្រុមហ៊ុនអេមរ៉ាយស៍ខេមបូឌា ចូលរួមក្នុងវិធីខាងលើ តាមប្រព័ន្ធអនឡាញ

- របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-អូស្ត្រាលី ដើម្បីត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ឧត្តមមន្ត្រីកម្ពុជា-អូស្ត្រាលី លើកទី៣
- សំណើសុំចាត់ឧត្តមមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់អំពីការអនុវត្ត Key Deliverable និងបច្ចុប្បនភាពការងារតាមវិស័យនីមួយៗក្រោមសហគមន៍សង្គម-វប្បធម៌អាស៊ាន
- សំណើសុំរូបថតសម្រាប់រៀបចំបោះពុម្ពសៀវភៅស្តីពីការចូលរួមចំណែករបស់កម្ពុជាក្នុងអាស៊ាន និងពិព័ណ៌រូបថតសម្រាប់អបអរសាទរខួបលើកទី៥៥នៃការបង្កើតអាស៊ាន
- សំណើសុំអនុញ្ញាតអោយឧត្តមមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ានចូលរួមវេទិកាអាស៊ាន-ចិនលើកទី១៦ស្តីពីការអភិវឌ្ឍន៍សង្គមនិងកាត់បន្ថយភាពក្រីក្រតាមប្រព័ន្ធអនឡាញ
- បានរៀបចំលិខិតឆ្លើយតបទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិស្តីពីរបាយការណ៍វឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងបណ្តាប្រទេសអាស៊ីប៉ូស៊ីហ្វិក
- បានរៀបចំលិខិតឆ្លើយតបទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិស្តីពីរបាយការណ៍វឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-អូស្ត្រាលី និងកម្ពុជា-នូវែលសេឡង់
- បានរៀបចំលិខិតឆ្លើយតបទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីរបាយការណ៍វឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-ឥណ្ឌា

**៣.ផ្សេងៗ**

- កាលថ្ងៃទី ១៩ ដល់ថ្ងៃទី ២២ ខែមករា បានចុះពិនិត្យការងារសមិទ្ធផលរបស់អង្គការ ស៊ី ប៊ិន អិន កម្ពុជា នៅខេត្តប៉ៃលិន
- កាលថ្ងៃទី ០៩ ដល់ថ្ងៃទី ១២ ខែមីនា បានចុះពិនិត្យការងារសមិទ្ធផលរបស់អង្គការ World Hopeនៅខេត្តមណ្ឌលគិរី
- កាលថ្ងៃទី ២២ ដល់ថ្ងៃទី ២៥ ខែមីនា បានចុះពិនិត្យការងារសមិទ្ធផលរបស់អង្គការ ការីតាសអូស្ត្រាលី និងអង្គការចេរភាព នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង
- កាលថ្ងៃទី ២៩ ដល់ថ្ងៃទី ៣១ ខែមីនា បានចុះពិនិត្យការងារសមិទ្ធផលរបស់អង្គការ វើលវីញ នៅខេត្តបន្ទាយមានជ័យ
- បានរៀបចំសំណើសុំចូលរួមជាគណៈអធិបតីក្នុងកម្មវិធីប្រគល់ និងបិទបញ្ចប់គម្រោងទឹកស្អាត និងអនាម័យ
- បានរៀបចំរបាយការណ៍ស្តីពី ការចុះពិនិត្យ និងវាយតម្លៃពីសមិទ្ធផលរបស់អង្គការ World Hope International
- បានរៀបចំសំណើសុំហត្ថលេខា លើលិខិតជូនដំណឹងស្តីពីការអនុវត្តសកម្មភាពការងារសាងសង់ផ្ទះជួយសហគមន៍របស់ អង្គការលំនៅឋានមនុស្សជាតិអន្តរជាតិកម្ពុជា ក្នុងខេត្តស្វាយរៀង
- បានរៀបចំសំណើសុំហត្ថលេខា លើបណ្ណសរសើរជូនអង្គការសាម៉ារីតាន់ ភើសសង្គ្រោះអន្តរជាតិ
- កាលថ្ងៃទី ១០ ដល់ថ្ងៃទី ១២ ខែឧសភា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តក្រចេះ

- កាលថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែឧសភា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តត្បូងឃ្មុំ
- កាលថ្ងៃទី ២៣ ដល់ថ្ងៃទី ២៥ ខែឧសភា បានចុះពិនិត្យការងារសមិទ្ធផលរបស់អង្គការ Clear Cambodia នៅខេត្តបាត់ដំបង
- សំណើសុំហត្ថលេខា លើលិខិតគាំទ្រនាំចូលដែលលាងដៃ និងប្រេងរឹតសាច់ដុំ ពីសាធារណរដ្ឋសិង្ហបុរី របស់ក្រុមហ៊ុនBorden Company
- សំណើសុំអនុញ្ញាតនាំចូលដែលលាងដៃចំនួន ១០៦៥កេះ ទម្ងន់ ៩ ៤៥៣,៤៦០គីឡូក្រាម មានតម្លៃសរុប ១០០ ៦០៨ដុល្លារអាមេរិក នាំចូលតាមច្រកកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ ដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ របស់ក្រុមហ៊ុនBorden Company ទៅគយ។
- សំណើសុំអនុញ្ញាតនាំចូលដែលលាងដៃចំនួន ១០៦៥កេះ ទម្ងន់ ៩ ៤៥៣,៤៦០គីឡូក្រាម មានតម្លៃសរុប ១០០ ៦០៨ដុល្លារអាមេរិក នាំចូលតាមច្រកកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ ដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ របស់ក្រុមហ៊ុនBorden Company ទៅក្រសួងសុខាភិបាល
- សំណើសុំអនុញ្ញាតនាំចូលដែលលាងដៃចំនួន ១០៦៥កេះ ទម្ងន់ ៩ ៤៥៣,៤៦០គីឡូក្រាម មានតម្លៃសរុប ១០០ ៦០៨ដុល្លារអាមេរិក នាំចូលតាមច្រកកំពង់ផែអន្តរជាតិខេត្តព្រះសីហនុ ដោយការបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ របស់ក្រុមហ៊ុនBorden Company ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលប្រជុំលើកទី២ ស្តីពីការត្រួតពិនិត្យ ការរៀបចំគម្រោងសំណើរ) Project Concept Paper ឬ Express of Interest ) សម្រាប់ជុំទី៦ ក្នុងក្របខ័ណ្ឌមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ Mekong-Rok ( MKCF )
- សំណើសុំបញ្ជូនឯកសារទស្សនទានគម្រោង Projet Concept Paper សម្រាប់ជុំទី៦ក្នុងក្របខណ្ឌមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ) MKCF)
- កាលថ្ងៃទី ១៥ ដល់ថ្ងៃទី ១៧ ខែមិថុនា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តកំពង់ធំ។
- កាលថ្ងៃទី ១៥ ដល់ថ្ងៃទី ១៧ ខែមិថុនា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តពោធិ៍សាត់
- សំណើសុំគោលការណ៍រៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងណែនាំពីការរៀបចំរបាយការណ៍ និងសំណើគម្រោងថ្មីឆ្នាំ២០២៣-២០២៤) Project Proposal) ពីរដ្ឋាភិបាលអាល្លឺម៉ង់
- កាលថ្ងៃទី ០៦ ដល់ថ្ងៃទី ០៩ ខែកក្កដា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តសៀមរាប
- កាលថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែកក្កដា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តព្រះសីហនុ
- កាលថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែកក្កដា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តកំពង់ចាម

- កាលថ្ងៃទី ២២ ដល់ថ្ងៃទី ២៥ ខែសីហា បានចុះពិនិត្យនៃការប្រមូលទិន្នន័យរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទនៅខេត្តពោធិ៍សាត់បាត់ដំបង និងខេត្តបន្ទាយមានជ័យ ,
- សំណើសុំគោលការណ៍រៀបចំសិក្ខាសាលា ស្តីពី វឌ្ឍនភាពការងារសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ចាប់ពីឆ្នាំ២០១៨-២០២២ និងបូកសរុបរបាយការណ៍ឆមាសទី១ ឆ្នាំ២០២២។
- សំណើសុំបញ្ជូនឯកសារគម្រោងផ្គត់ផ្គង់ទឹកសុវត្ថិភាពជនបទ ចំនួន ០១គម្រោង ក្រោមហិរញ្ញប្បទានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ) KOICA)
- សំណើសុំបញ្ជូនរបាយការណ៍គម្រោងមេគង្គ-ឡានឆាងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានរៀបចំរបាយការណ៍សិក្ខាសាលា ស្តីពីលទ្ធផលការងារសហប្រតិបត្តិការ ជាមួយអង្គការមិនមែនរដ្ឋាភិបាល រយៈពេល ៥ឆ្នាំ) ២០១៨-២០២២ (និងបូកសរុបរបាយការណ៍ឆមាសទី១ ឆ្នាំ២០២២
- សំណើសុំធ្វើសវនកម្មលើឯកសារគម្រោងក្រោមមូលនិធិពិសេស នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។
- សំណើសុំគោលការណ៍រៀបចំសិក្ខាសាលាស្តីពីការបូកសរុបរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់NGOs
- រៀបចំរបាយការណ៍ចូលរួមសិក្ខាសាលាស្តីពី ផែនការយុទ្ធសាស្រ្តឆ្នាំ២០២៣-២០២៥របស់អង្គការឆាល ហ្វានកម្ពុជា
- រៀបចំរបាយការណ៍បូកសរុបការងារអង្គការមិនមែនរដ្ឋាភិបាលប្រចាំឆ្នាំ២០២២

4.**បញ្ហាប្រឈម**

- ថវិកាសម្រាប់ចុះបំពេញបេសកកម្មមានចំនួនតិចមិនអាចចុះបំពេញការងារនៅតាមរាជធានីខេត្តបានគ្រប់គោលដៅ
- លំហូរថវិកាមានភាពយឺតយ៉ាវធ្វើឲ្យកិច្ចប្រតិបត្តិការមិនទាន់ពេលវេលា
- របាយការណ៍ផ្ញើរពីគ្រប់អង្គភាពមានភាពយឺតយ៉ាវពុំអាចបូកសរុបបានទាន់ពេលវេលា
- របនាសម្ព័ន្ធថវិកាកម្មវិធីមានការផ្លាស់ប្តូរធ្វើឲ្យការរៀបចំផែនការមិនទាន់ពេលវេលា

5.**ទិសដៅការងារឆ្នាំ២០២៣**

- ពិនិត្យនិងកែសម្រួលគោលនយោបាយក្រសួងអភិវឌ្ឍន៍ជនបទ
- រៀបចំផែនការវិនិយោគសាធារណៈបីឆ្នាំរំកិលឆ្នាំ២០២៤-២០២៦
- រៀបចំផែនការយុទ្ធសាស្រ្តថវិកាបីឆ្នាំរំកិលឆ្នាំ២០២៤-២០២៦
- រៀបចំផែនការថវិកាព័ត៌មានសមិទ្ធកម្មឆ្នាំ២០២៤
- រៀបចំផែនការអភិវឌ្ឍន៍វិស័យជនបទសម្រាប់នីតិកាលទី៧ ឆ្នាំ២០២៣-២០២៨
- រៀបចំសៀវភៅការគ្រប់គ្រងការចំណាយប្រចាំខែ (Financial Management Manual ,FMM)
- បណ្តុះបណ្តាលការរៀបចំ KPI , Output Indicator , Outcome Indicator, Set Program Goal
- បណ្តុះបណ្តាលវិធីសាស្រ្តគណនាប្រាក់បៀវត្សរ៍តាមអនុកម្មវិធី និងកម្មវិធី
- បន្តរៀបចំស្ថិតិអភិវឌ្ឍន៍ជនបទ

- កែសម្រួលទម្រង់បែបបទរបាយការណ៍សមិទ្ធកម្ម KPI Report
- សមាហរណកម្មគម្រោងវិនិយោគថវិការជួននិងថវិកាចរន្ត និងថវិកាដៃគូរសហប្រតិបត្តិការ
- ចុះតាមដាននិងវាយតម្លៃការអនុវត្តសូចនាករសមិទ្ធកម្មថវិកាកម្មវិធី
- កែសម្រួលកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងទម្រង់ របាយការណ៍របស់អង្គការ
- ចុះតាមដាននិងវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងជាមួយអង្គការមិនមែនរដ្ឋាភិបាលរៀងរាល់ត្រីមាស និងប្រចាំឆ្នាំ
- សម្របសម្រួលឯកសារគតិយុត្តិផ្សេងៗជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រៀបចំលិខិតឆ្លើយតប និងសម្របសម្រួលការងារអាស៊ាន អង្គការសហប្រជាជាតិ អាស៊ានបូក
- ពង្រឹងការរៀបចំប្រព័ន្ធគ្រប់គ្រងអ៊ីនធឿណែតក្រសួង
- បញ្ចូលទិន្នន័យ កែលម្អ និងបង្ហោះទិន្នន័យ ព័ត៌មានក្រសួងចូលក្នុងវេបសាយ និងអេបក្រសួង
- ចូលរួមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយទៀងទាត់
- ប្រជុំត្រួតពិនិត្យនាយកដ្ឋានប្រចាំត្រីមាស និងប្រចាំឆ្នាំ

**សេចក្តីសន្និដ្ឋាន**

ការងារផែនការ និងទំនាក់ទំនងសាធារណៈមានវិសាលភាពធំជាងគេបើប្រៀបធៀបនឹងអង្គ ភាពនាយកដ្ឋានដូចគ្នានៅក្រសួងអភិវឌ្ឍន៍ជនបទ ។ សកម្មភាពការងាររបស់នាយកដ្ឋានគឺទំនាក់ទំនង ផ្តល់សេវាដល់ភាគដទៃទៀតដើម្បីសម្រួលដល់ការងារប្រចាំថ្ងៃក៏ដូចជាការងារអភិវឌ្ឍន៍ក្នុងវិស័យជនបទដែរ ។ ទោះជាស្ថិតក្នុងកាលៈទេសៈនៃការរាតត្បាតជំងឺកូវីដ១៩ ក៏ដោយ ក៏នាយកដ្ឋាននៅតែអាចទំនាក់ទំនង ប្រជុំពិភាក្សា សិក្ខាសាលាតាមរយៈអនឡាញផង និងផ្ទាល់ផងដោយធ្វើយ៉ាងណាផ្ទេរចំណេះជំនាញ ផែនការ ថវិកា របាយការណ៍ ។ល។ ទៅឲ្យបណ្តាអង្គភាពផ្សេងៗដើម្បីប្រតិបត្តិតាមច្បាប់ជាធរមាន ។ តាមការវាយតម្លៃក្នុងកិច្ចប្រតិបត្តិការផែនការឆ្នាំ២០២២នេះ នាយកដ្ឋានបានសម្រេចគ្រប់គោលដៅដែលបានកំណត់ ១០០% ។ កិច្ចការនេះ អាចសម្រេចទៅបានដោយ មានការ ចង្អុលបង្ហាញតម្រង់ទិសពីសំណាក់ **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ដើម្បីជាមាគ៌ាឆ្ពោះ ទៅរកគោលដៅដែលជាគោលបំណងគោលនយោបាយរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ៕